# តើអ្នកគួរតែចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B ដែរទេ?



- រោគរលាកថ្លើមប្រភេទ B គឺជាវីរុសដែលវាយប្រហារថ្លើម និងអាចបង្កជាមហារីកថ្លើម។
- មនុស្សជាច្រើនមិនដឹងខ្លួនថាបានឆ្លងមេរោគ ដោយសារពួកគេមិនមានអារម្មណ៍ ឬមើលទៅដូចជាមានជំងឺទេ ប៉ុន្តែពួកគេអាចចម្លងមេរោគនេះទៅអ្នកដទៃបាន។
- មានវ៉ាក់សាំងដែលមានប្រសិទ្ធភាព និងសុវត្ថិភាពដែលអាចបង្ការរោគរលាកថ្លើមប្រភេទ B។ អ្នកត្រូវចាក់ឱ្យបានគ្រប់ចំនួន ទើបអាចការពារបានពេញលេញ។

## រោគរលាកថ្លើមប្រភេទ B ចម្លងតាមរយៈ៖

- មនុស្សមានផ្ទៃពោះទៅទារក អំឡុងពេលសម្រាលកូន
- ការប៉ះពាល់ផ្លូវភេទ
- ការប៉ះពាល់ឈាមរបស់មនុស្សដែលបានឆ្លងរោគ
- ការប្រើផ្លែឡាម ច្រាសដុសធ្មេញ ឬកន្ត្រៃកាត់ក្រចករួមគ្នា

## តើនរណាខ្លះគួរចាក់វ៉ាក់សាំង?

- ទារកគ្រប់រូប
- កុមារ និងមនុស្សពេញវ័យអាយុរហូតដល់ 59 ឆ្នាំដែលមិនបានចាក់វ៉ាក់សាំងគ្រប់រូប ដោយមិនគិតពីកត្តាហានិភ័យផ្សេងៗ
- មនុស្សពេញវ័យអាយុ 60 ឆ្នាំឡើងទៅដែលមានកត្តាហានិភ័យដូចជា៖
  - ការប៉ះពាល់ផ្លូវភេទ
  - ការចាក់ថ្នាំតាមស្បែក ឬភ្នែក/មាត់/ច្រមុះប៉ះពាល់ជាមួយនឹងឈាម
  - ធ្វើដំណើរទៅតំបន់ដែលរោគរលាកថ្លើមប្រភេទ B មានអត្រាឆ្លងមធ្យមឬខ្ពស់
  - ឆ្លងវីរុស HIV ឬជំងឺថ្លើមរ៉ាំរ៉ៃ

សម្រាប់ព័ត៌មានបន្ថែម៖

**www.cdc.gov/hepatitis/hbv/**
**doh.wa.gov/hepbhub**

Hep B Hub
doh.wa.gov/hepbhub

Washington State Department of Health DOH 420-407 May 2022 Khmer

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

បានកែសម្រួលដោយមានការអនុញ្ញាតពី Minnesota Department of Health (ក្រសួងសុខាភិបាលនៃរដ្ឋមីណេសូតា)